# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការ
## ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើតក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | អ៊ុយ ស៊ីម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | ប្រធាន |
| ២- ឯកឧត្តម | ខៀវ សុភ័គ | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

www.pheakdeylaw.com

៣- ឯកឧត្តម **ឈឹម មង្គល** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង លេខាធិការ

**ប្រការ ២.-** ភារកិច្ចរបស់ក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការ :

- ពាំនាំនូវបញ្ហា និងសេចក្តីណែនាំនានារបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូនឯកឧត្តម លោកជំទាវ អស់លោក ជាទីប្រឹក្សា ជំនួយការ ដើម្បីអនុវត្ត
- ពិនិត្យ និងផ្តល់យោបល់លើរាល់កិច្ចការ សំណុំឯកសារ លិខិត ឬសំណើនានារបស់ទីប្រឹក្សា ជំនួយការ ដែលត្រូវសុំយោបល់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ពិនិត្យ និងវាយតម្លៃលើស្នាដៃការងាររបស់ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការ ជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គ្រប់គ្រងសំណុំឯកសារផ្ទាល់ខ្លួនរបស់ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការ
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៣.-** ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាំងអស់ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៩

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com